# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ២២៤.៣.១.១០២-៩៧

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ប្រធានតុលាការគ្រាប់ខេត្ត ក្រុង**

**សូមជ្រាប**

***កម្មវត្ថុ:*** ការផ្តល់សម្រង់សាលក្រម ឬដីកាលើកលែងចោទប្រកាន់លើមន្ត្រីរាជការជូនដល់ក្រសួងរបស់សាមីជន ។

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា តុលាការគ្រប់ខេត្តក្រុងមិនទាន់បានយកចិត្តទុកដាក់ជូនដំណឹងអំពីការវិនិច្ឆ័យទោស ឬការលើកលែងចោទប្រកាន់ទណ្ឌិតឬជនសង្ស័យថាជាជនល្មើសជូនដល់សាមីក្រសួងរបស់ជនទាំងនោះដែលអយ្យការបានសុំអនុញ្ញាតធ្វើការចោទប្រកាន់នៅឡើយ ។

ក្រសួងសូមអស់លោកចម្លងសម្រង់សាលក្រម ឬដីកាលើកលែងចោទប្រកាន់ជូនទៅក្រសួងរបស់សាមីជនអោយបានឆាប់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**